ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៧២ សហវ.ក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់បន្ទាន់ដែលចង់ប្រាក់

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ១៤០៥ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងកិច្ចដំណើរការគណនីនៃរជ្ជទេយ្យចំណូល
- បានឃើញសារាចរណែនាំលេខ ០១៣ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរជ្ជទេយ្យចំណូល
- តាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាពេលបច្ចុប្បន្ន

## សម្រេច

**ប្រការ ១** : ត្រូវបានដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលមានទម្រង់ឯកភាព និងបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានគំរូជូនភ្ជាប់នឹងប្រកាសនេះ។

**ប្រការ ២** : បង្កាន់ដៃបង់ប្រាក់ ចែកចេញជាពីរប្រភេទ ៖

- បង្កាន់ដៃបង់ប្រាក់ប្រភេទ ១ មានគំរូលេខ ០១ សហវ/ចមព : ប្រើប្រាស់ជាទូទៅសម្រាប់ការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលមានតម្លៃប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈនៃសេវាសាធារណៈរបស់រដ្ឋ។
- បង្កាន់ដៃបង់ប្រាក់ប្រភេទ ២ មានគំរូលេខ ០២ សហវ/ចមព : សម្រាប់ប្រើប្រាស់ផ្តោតលើការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធទាំងឡាយណាដែលមានតម្លៃសេវាដូចៗគ្នា ផ្តល់លទ្ធភាពដល់ការបោះពុម្ពតម្លៃស្រេចជាមុននៅលើបង្កាន់ដៃបង់ប្រាក់ និងគ្មានការចាំបាច់តម្រូវឱ្យសរសេរបំពេញព័ត៌មានអ្វីឡើយ។

**ប្រការ ៣** : បង្កាន់ដៃបង់ប្រាក់ប្រភេទ ១ ត្រូវបានបោះពុម្ពចងក្រងជាសៀវភៅ មានដាក់លេខកូដក្បាលសៀវភៅ និងលេខរៀងបង្កាន់ដៃ។ សៀវភៅបង្កាន់ដៃមួយក្បាលៗមានបង្កាន់ដៃបង់ប្រាក់សរុបចំនួន ៥០ (ហាសិប) និងបង្កាន់ដៃបង់ប្រាក់នីមួយៗបោះពុម្ពឡើងជា ៣(បី)ច្បាប់ត្រួតជាប់គ្នា ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី ១ មានពណ៌ស ជាច្បាប់ដើម សម្រាប់ទុកជាសក្ខីប័ត្រភ្ជាប់សំណុំរឿង
- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី ២ មានពណ៌ផ្ទៃមេឃ ជាច្បាប់ចម្លង សម្រាប់ប្រគល់ជូនអ្នកបង់ប្រាក់
- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី ៣ មានពណ៌ផ្កាឈូក ជាច្បាប់ចម្លង សម្រាប់រក្សាទុកនៅជាប់នឹងក្បាលសៀវភៅ។

**ប្រការ ៤** : បង្កាន់ដៃបង់ប្រាក់ប្រភេទ ២ ត្រូវបានបោះពុម្ពចងក្រងជាសៀវភៅ មានដាក់លេខកូដក្បាលសៀវភៅ និងលេខរៀងបង្កាន់ដៃ។ សៀវភៅបង្កាន់ដៃមួយក្បាលៗ មានបង្កាន់ដៃសរុបចំនួន ២០០(ពីររយ) និងបង្កាន់ដៃនីមួយៗបោះពុម្ពឡើងជា ៣(បី)ច្បាប់ស្ថិតនៅបន្តបន្ទាប់គ្នាលើសន្លឹកតែមួយ និងមានពណ៌ស្វាយដូចៗគ្នាទាំងអស់។ ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រភេទ ២ ត្រូវបានកំណត់ដូចតទៅ ៖

- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកខាងចុង សម្រាប់ប្រគល់ជូនអ្នកបង់ប្រាក់
- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកកណ្តាល សម្រាប់ទុកជាសក្ខីប័ត្រភ្ជាប់សំណុំរឿង
- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកខាងគល់ សម្រាប់រក្សាទុកនៅជាប់នឹងក្បាលសៀវភៅ។

**ប្រការ ៥** : នាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់អំពីទម្រង់ លក្ខណបច្ចេកទេស និងបរិមាណនៃបង្កាន់ដៃបង់ប្រាក់ និងធ្វើកិច្ចសហការជាមួយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការបោះពុម្ពបង្កាន់ដៃបង់ប្រាក់តាមនីតិវិធីហិរញ្ញវត្ថុ។

**ប្រការ ៦** : ការគ្រប់គ្រង និងការបើកផ្តល់បង្កាន់ដៃបង់ប្រាក់ ស្ថិតក្រោមការចាត់ចែងរបស់នាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៧** : រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល នៃក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរ និងអង្គភាព នៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលមានទម្រង់ឯកភាព និងបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការប្រមូលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ដើម្បីជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់ពីបានទទួលប្រាក់ចំណូល រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ត្រូវចេញបង្កាន់ដៃបង់ប្រាក់មួយច្បាប់ប្រគល់ជូនទៅអតិថិជន។

**ប្រការ ៨** : សេចក្តីណែនាំលម្អិតលើការបោះពុម្ព ការបើកផ្តល់ ការប្រើប្រាស់ ការកត់ត្រាតាមដាន និងការធ្វើរបាយការណ៍ស្តីពីបង្កាន់ដៃបង់ប្រាក់ នឹងកំណត់ដោយសារាចរណែនាំមួយដោយឡែក។

**ប្រការ ៩** : ករណីប្រព្រឹត្តអំពើល្មើសទៅនឹងខ្លឹមសារប្រការ ៧ នៃប្រកាសនេះ រួមទាំងការអនុវត្តប្រមូលចំណូលដោយប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ក្លែងបន្លំ នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីផ្សេងទៀត។

**ប្រការ ១០** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ តទៅ។

**ប្រការ ១២** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតក្រោមឱវាទក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១១

គាត ឈន់

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល
- រដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត
- រតនាគាររាជធានី ខេត្ត
- ឯកសារ - កាលប្បវត្តិ